# ប្រវត្តិដំបូងនៃព្រះពុទ្ធសាសនានៅប្រទេសខ្មែរ

## រៀបរៀងដោយ ជេម សុខ

*ថ្ងៃច័ន្ទទី ១ ខែឧសភា គ.ស. ២០០៦*

ប្រជាជនខ្មែរភាគច្រើនជាអ្នកគោរព និងប្រតិបត្តិព្រះពុទ្ធសាសនា ។ ព្រះពុទ្ធសាសនាខ្មែរបច្ចុប្បន្ន ហៅថា ព្រះពុទ្ធសាសនាថេរវាទ ដែលតាមភាសាអង់គ្លេសហៅថា **Theravada Buddhism** ។

ចាប់តាំងពីប្រកាសឲ្យប្រើរដ្ឋធម្មនុញ្ញដំបូងនៅឆ្នាំ១៩៤៧ មកម្ល៉េះ រដ្ឋបានប្រកាសព្រះពុទ្ធសាសនា ជាសាសនារបស់រដ្ឋខ្មែរ (មាត្រា ៨, វាក្យខ័ណ្ឌ ៣ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា, ព្រះមហាក្សត្រឡាយព្រះហស្ថលេខាឲ្យប្រើនៅថ្ងៃទី ៦ ខែឧសភា គ.ស. ១៩៤៧) ។

ព្រះពុទ្ធសាសនា កើតឡើងពីដំបូងនៅឯប្រទេសឥណ្ឌា នាសម័យបូរម បុរាណប្រមាណជាង ២.៥០០ កន្លងមកហើយ ។ ស្ថាបនិកនៃសាសនានេះមានព្រះនាមថា ព្រះសមណៈគោត្តម ។ ព្រះអង្គជាមនុស្សកើតក្នុងលោកយើងនេះ ហើយបានស្រាវជ្រាវរកឃើញ នូវការត្រាស់ដឹងដោយបរិបូរណ៍ ។

ក្រោយពីបានត្រាស់ដឹងដោយបរិបូរណ៍រួចហើយ ព្រះសមណៈគោត្តម ក៏បានតាក់តែងរៀបចំបង្កើតឡើង នូវសាសនាមួយរបស់ព្រះអង្គ ដែលសព្វថ្ងៃនេះយើងហៅថា ព្រះពុទ្ធសាសនា នេះឯង ។

### ប្រវត្តិដំបូងនៃព្រះពុទ្ធសាសនានៅប្រទេសខ្មែរ

យោងតាមលោកបណ្ឌិត សុង ស៊ីវ ក្នុងសៀវភៅនិពន្ធទី ៣៨ របស់លោកឈ្មោះ ពុទ្ធសាសនា និងវិទ្យាសាស, បណ្ណាគារតើមតី ក្រុងភ្នំពេញ, គ.ស. ១៩៧២ ទំព័រ ៣២ ដល់ទំព័រ ៤០ អធិប្បាយថា ៖ បណ្ដាប្រទេសដែលកាន់ពុទ្ធសាសនានៅជិតគ្នាសព្វថ្ងៃគឺប្រទេសខ្មែរ, សៀម, លាវ, និងយួន ទាំង ៤ នេះ មានតែប្រទេសខ្មែរមួយទេ ដែលបានទទួលគោរពពុទ្ធសាសនាមុនគេបំផុត តាំងពីមុនសម័យនគរភ្នំ (ហ្វូណន) ជាច្រើនរយឆ្នាំ គឺតាំងពីព្រះអរហន្តព្រះនាម **មោគ្គលីបុត្តស្សត្ថេរ** បញ្ជូនសមណទូតមក ។ ព្រោះថានៅអាស៊ីភាគអាគ្នេយ៍ដែលហៅថាដែនដីសុវណ្ណភូមិនេះ ជាភូមិភាគនៅចន្លោះចិន និងឥណ្ឌា ។ ក្នុងភូមិភាគជាចន្លោះទាំងមូលនេះ មានតែប្រជាជាតិ ៣ ទេ ដែលជាម្ចាស់ដើមរបស់សុវណ្ណភូមិ គឺខ្មែរ, មន, ចាម, និងជ្វាម៉ាឡាយូមួយទៀតស្ថិតនៅលើប្រជុំកោះ ។

ឯភូមា, សៀម, លាវ និងយួនជាដើមនោះមិនទាន់កើតមានពូជជាតិក្នុងលោកនៅលើទឹកដីសុវណ្ណភូមិ អាស៊ីអាគ្នេយ៍នៅឡើយ ។

**គម្ពីរបឋមសាមន្តប្បាសាទិកា - គម្ពីរមហាវង្ស** ដែលផ្សាយចេញពីប្រកពកោះសិរីលង្កានោះ ប្រាប់ថាក្នុង ព.ស. ២៣៤ គឺក្នុងពុទ្ធសតវត្សរ៍ទី ៣ (មុន គ.ស. ៣០៩ ឆ្នាំ), ក្រោយពេលធ្វើ **តតិយសង្គាយនា** ក្រោមព្រះរាជជូបត្ថម្ភ នៃ **ព្រះបាទធម្មាសោក** នាមគធរដ្ឋហើយ ព្រះអរហន្តព្រះនាម **មោគ្គលីបុត្តតស្ស-ត្ថេរ** បានបញ្ជូន **ព្រះសោណត្ថេរ** និង **ព្រះឧត្តរត្ថេរ** មកកាន់សុវណ្ណភូមិ (អាស៊ីអាគ្នេយ៍) យើងនេះ ។ ប៉ុន្តែក្នុងគម្ពីរនោះមិនបានប្រាប់ឲ្យច្បាស់ថា ក្នុងសម័យដែលពុទ្ធសាសនាចូលមកប្រទេសខ្មែរជាដំបូងបំផុតក្នុងរជ្ជកាលណា, រាជធានីខ្មែរតាំងនៅកន្លែងណាទេ ព្រោះជាសម័យបុរេប្រវត្តិសាស្ត្រ មុនប្រវត្តិសាស្ត្រខ្មែរយើង ។

ក្នុងសៀវភៅនិពន្ធដោយព្រះភិក្ខុ **ប៉ាំង ខាត់** ឈ្មោះ ព្រះពុទ្ធសាសនានៅប្រទេសកម្ពុជា, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ ព.ស. ២៥០៤ បានអធិប្បាយឲ្យដឹងថា នៅក្រោយព្រះពុទ្ធបរិនិព្វានទៅ បានប្រមាណជា ២១៨ ឆ្នាំ មានព្រះរាជាមួយអង្គព្រះនាម **ព្រះបាទធម្មាសោកមហារាជ** បានឡើងសោយរាជ្យក្នុងរាជធានី **បាដលិបុត្រ** នៃមគធរដ្ឋ ប្រទេសឥណ្ឌា ព្រះរាជាអង្គនេះប្រកបដោយឫទ្ធានុភាពខ្លាំងក្លា ទ្រង់បានទទួលជឿក្នុងព្រះពុទ្ធសាសនាហើយបានក្លាយជា ព្រះសាសនូបត្ថម្ភក៍ក្នុងការធ្វើ **តតិយសង្គានា** នៅ ព.ស. ២៣៤ ។ លុះធ្វើតតិយសង្គាយនារួចហើយ ទ្រង់បានបញ្ជូនសមណៈទូតច្រើនអង្គទៅកាន់បច្ចន្តប្រទេសនានា ផុតពីដែនដីមជ្ឈមប្រទេស មុនដំបូងបង្អស់ក្នុងប្រវត្តិសាស្ត្រ នៃព្រះពុទ្ធសាសនា ។

គេបានដឹងតាមប្រកពកោះស្រីលង្កាថា ក្រោយពីធ្វើតតិយសង្គាយនារួចនោះ **ព្រះមោគ្គលិបុត្តតិស្សត្ថេរ** បានបញ្ជូន **ព្រះសោណត្ថេរ** និង **ព្រះឧត្តរត្ថេរ** ទៅផ្សព្វផ្សាយព្រះពុទ្ធសានាឯដែនដី **សុវណ្ណភូមិ** ។

តាមរយៈលោក **វ៉ាយ ប៊ុក** ក្នុងវណ្ណកម្មរបស់លោក មានចំណងជើងថា ព្រះពុទ្ធសាសនានៃប្រទេកម្ពុជា ការផ្សាយរបស់ **សមាគមមិត្តពុទ្ធិកវិទ្យាល័យ** នៅ គ.ស. ១៩៥៧ បានឲ្យដឹងថាព្រះពុទ្ធសាសនា បានចូលមកប្រតិស្ឋាននៅប្រទេសខ្មែរ ចាប់តាំងពីសតវត្សរ៍ទី ៣ នៃគ្រឹស្តសករាជ ដោយមានជនអន្តោ-ប្រវេសន៍ឥណ្ឌាជាអ្នកនាំមក ។

លោក Kanai Lal Hazra ក្នុងសៀវភៅស្រាវជ្រាវនិពន្ធរបស់លោកឈ្មោះ **History of Theravada Buddhism in South-East Asia** with special reference to India and Ceylon. Munshiram Manoharlal Publishers Ltd. 1981. ISBN 81-215-0164-4. page 73. បានអធិប្បាយអំពីកស្តុតាងបង្ហាញអំពីវត្តមានព្រះពុទ្ធសានានៅប្រទេសកម្ពុជា នាសម័យហ្វូណន នៅក្នុងរវាងសតវត្សរ៍ទី ៥ និងសតវត្សរ៍ទី ៦ នៃគ្រឹស្តសករាជ ។

ព្រះរាជាខ្មែរសម័យហ្វូណន ទ្រង់ជាអ្នកឧបត្ថម្ភគាំទ្រ ទាំងសាសនាព្រា-

ហ្មណ៍ និងព្រះពុទ្ធសាសនា ទោះបីព្រះរាជាគោរពបូជាចំពោះសាសនាព្រាហ្ម-ណ៍ក៏ដោយ ក៏ការគោរពប្រតិបត្តិព្រះពុទ្ធសាសនា នៅក្នុងសម័យនោះពុំមានការហាមឃាត់ ឬធ្វើទុក្ខបុកម្នេញអ្វីឡើយ ។

នៅ គ.ស. ៤៨៤ **ព្រះបាទកោឌិន្យៈជ័យវរ្ម័ន** (គ.ស. ៤៧៨ ដល់ គ.ស. ៥១៤) បានបញ្ជូនបេសកកម្មទូតមួយ ទៅក្រាបបង្គំទូលមហារាជក្រុងចិន ។ បេសកកម្មទូតនោះ ដឹកនាំដោយព្រះភិក្ខុសង្ឃព្រះពុទ្ធសាសនាព្រះនាម **នាគ-សេនា** (Nagasena) ។ យោងតាមបំណាកប្រែពីពង្សាវតាចិន នៃរាជវង្សមហា**លាង** (គ.ស. ៥០២ ដល់ គ.ស. ៥៥៦) របស់លោក P. Pelliot បានឲ្យដឹងថានៅ គ.ស. ៥០៣ **ព្រះបាទកោឌិន្យៈជ័យវរ្ម័ន** បានបញ្ជូនបេសកកម្មទូតមួយទៅកាន់ក្រុងចិន ដោយបាននាំយកទៅជាមួយ នូវព្រះពុទ្ធរូបចម្លាក់ពីផ្កាថ្មប៉្រាំងទៅថ្វាយអធិរាជក្រុងចិនព្រះនាម **វូទី** (Wu Ti) ដែលគោរពបូជាព្រះពុទ្ធសាសនា ។

ក្នុងសៀវភៅនិពន្ធរបស់ Ian Harris ឈ្មោះ **CAMBODIAN BUD-DHISM:** History and Practice. University of Hawaii Press. 2005. page 5-6 បានអធិប្បាយឲ្យដឹងថា ៖ នៅក្នុងរជ្ជកាលនៃ **ព្រះបាទកោឌិន្យៈជ័យវរ្ម័ន** ដដែលនេះ ក៏មានបញ្ជូនព្រះមហាថេរៈនគរហ្វូណនពីរព្រះអង្គ ព្រះនាម **សង្ឃបាល** ឬ **សង្ឃវរ្ម័ន** និង **មន្រ្ទៈសេនា** ឲ្យនិមន្តទៅក្រុងចិន ដើម្បីជួយបកប្រែព្រះត្រៃបិដកឲ្យចិន ។ ព្រះមហាថេរៈព្រះនាម **សង្ឃបាល** ជាអ្នកប្រាជ្ញចេះដឹងធម៌អាថ៌ និងភាសាជាច្រើនភាសា ព្រះអង្គបានគង់នៅឯស្រុកចិនធ្វើការផ្សាយព្រះពុទ្ធសាសនា ជាមួយព្រះមហាថេរៈព្រះនាម **មន្រ្ទៈសេនា** ។

ក្នុងសៀវភៅនិពន្ធរបស់លោក R.C. Majumdar ឈ្មោះ **KAMBUJA-DESA** or An Ancient Hindu Colony in Cambodia. ISHI. 1980. page 33. បានអធិប្បាយឲ្យដឹងថា ៖ *"Jayavarman sent two embassies to the imperial court, one in 511 and the other in 514 A.D.. There is no doubt that throughout his reign a very cordial and intimate relation subsisted between the two countries. This further proved by the fact that two Buddhist monks of Funan settled in China whose works are still preserved in the Tripitaka. One of them, Sanghapala or Sanghavarman (460-524 A.D.) knew several languages and spent sixteen years (506-522) in translating, at the command of the emperior Wu, various canonical texts in five different places. One of these was called Funan-Kuan or Bereau of Funan.*

*"The second monk was named Mandra or Mandrasena. He arrived at the imperial capital in A.D. 503, and was commanded by emperior Wu to collaborate with Sanghapala in the translation of sacred scriptures. "*

Lawrence Palmer Briggs ក្នុងសៀវភៅនិពន្ធរបស់គាត់ឈ្មោះ **THE ANCIENT KHMER EMPIRE**. Publication of The American Philosophical Society. 1951. page 29. បានអធិប្បាយអំពី *ពុទ្ធសាសនិកហ្វូណននៅរាជវាំងចិន ៖ <<ទោះបីជាអាណាចក្រហ្វូណន គោពរសក្ការៈចំពោះ ព្រះមហិស្វារៈ និងព្រះវិស្ណុ ក៏ដោយ ក៏គេអាចដឹងថាហ្វូណន គឺជាមជ្ឈមណ្ឌលពុទ្ធសាសនាខ្លាំង*

ក្លាមួយក្នុងរាជ្យព្រះបាទ (កោឌិន្យ:) **ជ័យវរ្ម័ន** សោយរាជ្យពី គ.ស. ៤៧៨ ឬមុននេះ ដល់ គ.ស. ៥១៤ ។ នៅក្នុងសម័យនោះ ភិក្ខុហ្វូណានពីរអង្គបានធ្វើដំណើរទៅកាន់ប្រទេសចិន ដើម្បីបកប្រែគម្ពីរពុទ្ធសាសនា ។ បំណកប្រែរបស់ភិក្ខុហ្វូនណានទាំងពីរអង្គនេះ ឮថានៅមានបោះផ្សាយក្នុងព្រះប្រៃបិដកចិន ។ ភិក្ខុមួយអង្គនាម **សង្ឃបាល** ឬសង្ឃវរ្ម័ន ប្រសូត្រនៅ គ.ស. ៤៦០ ធ្លាប់បានធ្វើដំណើរទៅប្រទេសចិនម្តង ក្នុងសម័យរាជវង្សមហា ឈី ។ ដោយភិក្ខុ **សង្ឃ-បាល** ចេះនូវភាសាច្រើនភាសា អធិរាជ វូ នៃរាជវង្សមហា **លាង** បានត្រាស់បង្គាប់ឲ្យព្រះអង្គបកប្រែគម្ពីរដីកា ។ ភិក្ខុ **សង្ឃបាល** បានរស់នៅប្រែគម្ពីរឯប្រទេសចិនអស់រយ: ១៦ ឆ្នាំ ។ ព្រះអង្គនិមន្តធ្វើការនៅទីកន្លែងការងារ ៥ កន្លែង ដែលមានមួយកន្លែងហៅថា ការិយាល័យហ្វូណាន ។ ភិក្ខុ **សង្ឃបាល** សុគតនៅឯប្រទេសចិន នៅ គ.ស. ៥២៤ ។ ចំណែកឯភិក្ខុមួយអង្គទៀតនាម **មន្ទ្រ: ឬ មន្ទ្រ:សេនា** ដែលនិមន្តទៅដល់ក្រុងចិននៅ គ.ស. ៥០៣ ។ អធិរាជ វូ បានត្រាស់បញ្ជារឲ្យព្រះអង្គធ្វើការជាមួយភិក្ខុ **សង្ឃបាល** ក្នុងកិច្ចការប្រែគម្ពីរ តែព្រះអង្គមិនសូវចេះចាំភាសាចិនជ្រៅជ្រះប៉ុន្មានទេ ។ ក្រៅពីនេះ មានភិក្ខុហ្វូណានជាច្រើនអង្គ បានធ្វើដំណើរទៅកាន់ប្រទេសចិន ។

យោងតាមពត៌មានខាងលើនេះ គេអាចដឹងបានថាវត្តមានព្រះពុទ្ធសាសនានៅប្រទេសកម្ពុជា នាសម័យហ្វូណាន ពិតជាមានការចំរើនលូតលាស់មែនទែន ព្រោះថាអ្នកបួសក្នុងព្រះពុទ្ធសាសនា មានចំណេះចេះដឹងគ្រប់គ្រាន់រហូតដល់ ព្រះរាជាព្រះអង្គអាចទុកចិត្តបាន ក្នុងទំនាក់ទំនងកិច្ចការទូតរវាងហ្វូណាន និងប្រទេសចិនកាលសម័យនោះ ។

**ព្រះបាទរុទ្រវរ្ម័ន** ទ្រង់ជាស្តេចឡើងសោរាជ្យបន្តពី **ព្រះបាទកោឌិន្យ:-វរ្ម័ន** ។ តាមប្រកពពង្សាវតាចិន នៃរាជវង្សមហា **លាង** The **Liang** Annal: **Story of Funan** , English translation published in **ANGKOR: The Khmers in Ancient Chinese Annals.** By Peter Wai-Chen. Oxford University Press. 2000. ISBN 019-592009-0. page 14. បានឲ្យដឹងថាព្រះរាជាអង្គនេះជាបុត្រព្រះស្នំ ទ្រង់បានធ្វើគត **ព្រះមកុដរាជកុមារ** (Crown Prince) ជារាជបុត្ររបស់ព្រះអគ្គមហេសីគឺព្រះនាង **កុលប្រភាវតី** ហើយទ្រង់ក៏ឡើងសោយរាជ្យក្នុង គ.ស. ៥១៤ ។

នៅ គ.ស. ៥១៧, ៥១៩, ៥២០, ៥៣០, ៥៣៥, និង ៥៣៩ ព្រះរាជអង្គនេះ បានបញ្ជូនបេសកកម្មទូតទៅកាន់ប្រទេសចិន ។ បេសកកម្មទូតនៅ គ.ស. ៥១៩ បាននាំគ្រឿងបណ្ណាការពិសេសមួយ ឆ្លាក់ពីឈើច័ន្ទក្រស្នាមកពីឥណ្ឌា បែបជាព្រះនាងសួស្តី (បដិមានាងទេវី?), ស្ទឹកពោធិព្រឹក្ស, គជខ្យង, គ្រឿងទេស, គ្រឿងក្រអូបផ្សេងៗជាច្រើនមុខ ទៅថ្វាយអធិរាជក្រុងចិន ។

នៅ គ.ស. ៥៣៩ ខាងបេសកកម្មទូតពីហ្វូណាន បានទូលថ្វាយអធិរាជក្រុងចិន វូទី អំពីសសៃព្រះកេសាព្រះពុទ្ធមួយសសៃប្រវែង ៣ ម៉ែត្រប្រតិស្ឋាន

នៅឯហ្វូណន ។ អធិរាជក្រុងចិនទ្រង់បានសព្វព្រះហឫទ័យ ក៏ត្រាស់បញ្ជាឲ្យព្រះមហាថេរចិនព្រះនាម **ជី យុនប៉ាវ** (Xi Yun Bao) ឲ្យនិមន្តមកហ្វូណនដើម្បីដង្ហែរព្រះកេសាព្រះពុទ្ធយកទៅកាន់ប្រទេសចិន ។

តាមរយៈសិលាចារឹកភាសាសំស្ក្រឹត នៅឯប្រាសាទតាព្រហ្មទន្លេបាទី ប្រ -ហែលសាងឡើង នៅក្នុងភាគកណ្តាលនៃសតវត្សរ៍ទី ៦ បានអធិប្បាយអំពី **ព្រះបាទកោឌិន្យៈជ័យវរ្ម័ន** និងបុត្រារបស់ព្រះអង្គគឺ **ព្រះបាទរុទ្រវរ្ម័ន** ។ ក្នុងគាថាមួយឃ្លា នៃសិលាចារិកនេះនិយាយអំពីព្រាហ្មណ៍ម្នាក់ ដែលថ្វាយខ្លួនជ្រកក្រោមម្លប់ព្រះរតនៈត្រៃជាឧបាសក និងមានសេចក្តីបួងសួងចំពោះព្រះសម្ពុទ្ធ ។

លោក Kannai Lal Hazra ក៏មានបញ្ជាក់រឿងរ៉ាវនេះដែរ ។ សូមអញ្ជើញអានខ្លឹមសារដូចតទៅនេះ ៖ *“A Sanskrit inscription found at Ta Prohm in the province of Bati in Southern Cambodia which refers to Jayavaraman and his son Rudravaraman, begins with an invocation to the Buddha. In another stanza there is reference to the Buddha, Dharma, and Sangha.”* -- [History of Tharavada Buddhism in South-East Asia. page 74.]

សេចក្តីអធិប្បាយជូនជ្រាបខាងលើនេះ គឺជាប្រវត្តិដំបូងនៃព្រះពុទ្ធសាសនានៅប្រទេសខ្មែរ ។ ខ្ញុំបាទជាអ្នករៀបរៀងសូមបញ្ចប់សេចក្តីនេះដោយសង្ខេបប៉ុណ្ណេះសិនចុះ ដោយសង្ឃឹមថាអស់លោកអ្នកអាន ប្រាកដជាអាចជ្រាបសេចក្តីច្បាស់ថា កំណាកំណើតព្រះពុទ្ធសាសនានៅប្រទេសខ្មែរ មិនមែនទើបនឹងកើត ឡើងនៅសម័យកាលភាគខាងចុង នៃសម័យមហានគរ ដូចអស់លោកខ្មែរយើងខ្លះស្មានៗនោះទេ ។ ព្រះពុទ្ធសាសនា ពិតជាបានមកដល់ប្រទេសខ្មែរចាប់ តាំងពីសម័យកាលដំបូរមបូរាណ ហើយខ្មែរយើងគឺពិតជាអ្នកទទួលគោរពប្រតិ បត្តិមុនគេឯងក្នុងដែនសុវណ្ណភូមិ មិនមែនយើងទទួលឥទ្ធិពលសាសនានេះពី សៀម ឬ ភូមារ ដូចអ្នកខ្លះនិយាយស្មានៗ មិនប្រាកដលើឯកសារប្រវត្តិសាស្រ្តនោះឡើយ ដូច្នេះសូមអស់លោកជាជនជាតិខ្មែរមេត្តាជ្រាប និងមេត្តាប្រឹងប្រែងសិក្សា អំពីវប្បធម៌ជាតិខ្មែរយើង ឲ្យបានហ្មត់ចត់កុំបីខានឡើយ ។ ៚